# ប្រវត្តិ

## ដងគើ

# អុំទូក - បណ្តែតប្រទីប
# សំពះព្រះខែ - អកអំបុក



ភ្នំពេញ

ព.ស ២៥៣៥ គ.ស ១៩៩១

ពុទ្ធសាសនបណ្ឌិត្យ
LIBRARY
BUDDHIST INSTITUTE
៦១៤.៣០
www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh        www.elibraryofcambodia.org**

www.budinst.gov.kh        www.elibraryofcambodia.org

៦១៤.៣០ ២៧៧/៩៥

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

# អារម្ភកថា

សៀវភៅ « ប្រវត្តិដងកើ និង បុណ្យរំឭក បណ្ដាលបុរីប បំពេញ ព្រះខែ អរករំបុក » នេះ គឺជាវណ្ណកម្មមួយកើតឡើង អាស្រ័យដោយការយកចិត្តទុកដាក់របស់គណៈបក្សប្រជាជនកម្ពុជា រដ្ឋាភិបាល នៃរដ្ឋកម្ពុជា និង រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ដែលបានអនុញ្ញាតជាគោល - ការណ៍ ឱ្យកសាងវេទិកាដ៏ប្រណីតមួយ ទុកជាសម្បត្តិវប្បធម៌ជាតិយូរអង្វែង ដោយរក្សានូវសោភណភាព ដូចប្រាសាទទាំងឡាយនៅក្នុងរាជវាំង និង កសាងឡើងវិញ នូវវិហារតូចពីរ ត្រង់ដងកើ ដែលត្រូវ វិនាសអន្តរាយក្នុងរបប ប៉ុល ពត ហើយរៀបចំឱ្យបានសមរម្យ ស្របនឹងការរីកចំរើនរបស់ រដ្ឋធានីភ្នំពេញ បើកឱកាសជូនប្រជាជនគោរពបូជាតាមជំនឿ ។

គណៈកម្មការសាងសង់មួយក៏ត្រូវបានបង្កើតឡើង ហើយចាប់ ដំណើរការសាងសង់ពី ថ្ងៃសុក្រ ១៥ រោច ខែផល្គុន ព.ស ២៥៣៥ ត្រូវនឹង ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩១ នឹងហើយស្រេចជាស្ថាពរ ប្រារព្ធពិធីសម្ពោធ បើកឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃ ពុធ ១៤ កើត ខែកត្តិក ព.ស ២៥៣៥ ត្រូវនឹងថ្ងៃ ២០ វិច្ឆិកា ឆ្នាំ ១៩៩១ មានតំលៃសរុប ១៨ លានរៀល ។

គណៈកម្មការកណ្ដាលរៀបចំពិធីបុណ្យ បានតម្រូវឱ្យខុទ្ទកាល័យ ក្រុមប្រឹក្សាជាតិរណសិរ្ស និង ក្រសួងឃោសនាការ វប្បធម៌ ស្រាវជ្រាវប្រវត្តិ ដងកើ និង វិហារទាំងពីរ ដើម្បីទុកជា ឯកសារ ជាគុណប្រយោជន៍ដល់ការ ស្រាវជ្រាវទៅអនាគត ។

www.budinst.gov.kh www.elibraryofcambodia.org

យើងខ្ញុំ អ្នកនិពន្ធអត្ថបទនេះ បានខិតខំស្វះស្វែងរាវរកឯកសារ មូលដ្ឋាន តាមបណ្ណាល័យ តាមវត្តអារាម តែពុំបានជួបប្រទះឯកសារណាមួយ និយាយពីប្រវត្តិដងកើសោះឡើយ ។ ប៉ុន្តែជាអំណោយផលម៉្យាង យើងខ្ញុំ ទទួលបានប្រវត្តិដងកើនេះ តាមរយៈការនិយាយផ្ទាល់មាត់ពីព្រះសង្ឃ គ្រហស្ថជាច្រើន ដែលបានដឹងរឿងនេះ ។

យើងខ្ញុំជឿជាក់ថា ទោះជាយ៉ាងណាក៏ដោយ អត្ថបទនេះនឹងផ្តល់ នូវគុណប្រយោជន៍យ៉ាងសំខាន់ដល់ការស្រាវជ្រាវ ស្តីពីជំនឿ ទំនៀមទម្លាប់ អធ្យាស្រ័យ សន្តានចិត្ត អត្តចរិត និង បំណងប្រាថ្នា របស់ជនជាតិមួយ គឺ « ជនជាតិខ្មែរ » ។

សូមឧទ្ទិសវណ្ណកម្មនេះ ជូនចំពោះវីរជនជាតិ កវី បណ្ឌិត ព្រះសង្ឃ គ្រហស្ថ សូមព្រលឹងស្នេហាជាតិ ស្នេហាវប្បធម៌ ប្រពៃណីរបស់ជាតិ ស្ថិតនៅជាប់ជានិច្ច ក្នុងមនសិការកូនខ្មែរគ្រប់រូប

សូមឥស្សរភាព សន្តិភាព និង ការបង្រួបបង្រួមជាតិ ស្ថិតស្ថេរជានិច្ច នៅលើមាតុភូមិទឹកដីអង្គរ នៃព្រោយសុវណ្ណភូមិ ។

**អ្នកនិពន្ធ**

www.budinst.gov.kh www.elibraryofcambodia.org

# ប្រវត្តិជងកើ

ឆ្នាំ ១៩៩១នេះ បក្ស រដ្ឋាភិបាលនៃរដ្ឋកម្ពុជា និងរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា បានអោយរៀបចំស្ថាបនាវេទិកាកិត្តិយសជាតិ « តំណាងអតីតថៃ » នៅមុខរាជវាំង ដើម្បីទុកជាសម្បត្តិវប្បធម៌ជាតិដ៏ទំនើបមួយសំរាប់បំរើក្នុងពិធីរៀបចំបុណ្យអុំទូក បណ្តែតប្រទីបថ្វាយលាដែលជាបុណ្យប្រពៃណីប្រចាំឆ្នាំរបស់ប្រជាជនកម្ពុជា ។

ជាមួយគ្នានេះ វិហារតូចពីរដែលរបបកម្ពុជាប្រជាធិបតេយ្យ បានបំផ្លាញខ្ទេចខ្ទីក្នុងអំឡុង ឆ្នាំ ១៩៧៥ - ១៩៧៨ ក៏ត្រូវបានអោយស្ថាបនាឡើងវិញ ដើម្បីបំរើដល់បុព្វហេតុនៃជំនឿរបស់ប្រជាជនផងដែរ ។ សំណង់ដ៏ប្រណីតទាំងពីរនេះ នឹងត្រូវបើកសម្ពោធអោយប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ ១៩៩១ ខាងមុខនេះ នាឱកាសបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ។

យើងរកពុំទាន់ឃើញឯកសារណាមួយ ជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើនិទស្សន៍ពីរឿងនេះសោះ ។ តែដើម្បីមិត្តអ្នកអានមានមូលដ្ឋានពិចារណាពីប្រភពដែលនាំអោយមានជងកើ « ជងទង់ » និងវិហារតូចពីរនៅមុខរាជវាំងនេះ យើងខ្ញុំបានសាកល្បងនិពន្ធអត្ថបទពីប្រវត្តិជងកើនេះ តាមរយៈការសាកសួរផ្ទាល់មាត់ពីចាស់ព្រឹទ្ធាចារ្យ ដែលធ្លាប់បំរើការនៅក្នុងវាំង និងព្រះសង្ឃ-គ្រហស្ថមួយចំនួនទៀត ដែលធ្លាប់រស់នៅទីក្រុងភ្នំពេញយូរហើយ ។ ឯព្រះសង្ឃ និង គ្រហស្ថ ដែលបានផ្តល់ពតិមានផ្ទាល់មាត់ ពីរឿង



www.budinst.gov.kh www.elibraryofcambodia.org

នេះ ក៏ពុំបានអះអាងថាពិតប្រាកដបានទេ គឺ គ្រាន់តែបានឮត ៗ គ្នា ។

ក្រោយការសាកសួរពីមួយទៅមួយមក យើងខ្ញុំទទួលបានប្រភពពតិមានបួនមានន័យប្រហាក់ប្រហែលគ្នា ពណ៌នាពីមូលហេតុដែលនាំអោយកើតមានដងកើ និងវិហារតូចពីរនៅមុខរាជវាំងនេះ ។

**ប្រភពពតិមានទី ១** : គឺបានពីលោក អ៊ុំ ហៀង នាយកបន្ទិរអប់រំរដ្ឋធានីភ្នំពេញបច្ចុប្បន្ន ។ លោកបានឮចាស់ ៗ ដំណាលប្រាប់លោកថា :

ដើមឡើយនៅត្រង់ដងកើនេះមានព្រៃនិងដើមឈើធំ ៗ ស្រោងជាកន្លែងមានឫទ្ធិបារមី ជាទីស្នាក់អាស្រ័យនៅនៃវត្ថុសក្តិសិទ្ធិផងទាំងពួង ។ មានគេនិយាយដំណាលត ៗ គ្នាថា រៀងរាល់ថ្ងៃពេញបូណ៌មី និងថ្ងៃខែដាច់នៃខែនិមួយ ៗ គេតែងឃើញទង់អណ្តែតពីបឹងទន្លេសាប មកផុសឡើងនៅកណ្តាលទន្លេមុខរាជវាំងនេះ ។ ទង់នោះមានសណ្ឋានជាទង់ក្អែប « ទង់ក្រពើ » មានដងតូយ តែនៅចុងដងមានបែកជាទង់បី ។ ប្រជាជនប្រុស - ស្រីតែងឃើញទង់ប្រភេទនេះផុសនៅទីនេះស្ទើរតែគ្រប់ ៗ គ្នា ។ រៀងរាល់ថ្ងៃសីល គេទាំងឡាយតែងនាំកូនចៅមោឈរចាំមើលទង់នេះផង និងតែងធ្វើពិធីបួងសួងប្រគុំភ្លេងពោបំណន់ ឬ ក៏បន់ស្រន់ ដើម្បីសុំជោគជ័យសិរីសួស្តីមង្គលវិបុលសុខគ្រប់ប្រការផង ។ តែទង់នោះមិនផុសឡើងអោយប្រជាជនឃើញយូរទេ គ្រាន់តែផុសឡើងមួយភ្លែត ៗ ប៉ុណ្ណោះ ហើយលិចបាត់ទៅវិញ ។

ចាស់ទុំយើងជំនាន់នោះ បានរៀបចំពិធីបួងសួងដោយពលីការផ្សេង ៗ មានស្លាធម៌ - បាយសី បង្អែម - ចំអាប ប្រគុំភ្លេងថ្វាយ ដើម្បីសុំអញ្ជើញអោយទង់សណ្ឋិតនៅទីនេះជានិច្ចកាលហើយនាំគ្នាធ្វើទង់មួយ ជានិមិត្តរូបនៃទង់ដែលផុស ហើយបានប្រកាសប្រតិស្ឋានទង់ជានិមិត្តរូបនេះ



www.budinst.gov.kh www.elibraryofcambodia.org

នៅត្រង់ដងកើ [១] នេះឯង ។ តាំងពីធ្វើពិធីនោះមក ទង់ដែលធ្លាប់ដែលផុស ក៏ លែងផុសទៀតរហូតមក ។ ដោយហេតុនេះ គេទាំងឡាយក៏កត់សំគាល់ ថា ទង់និមិត្តរូបដែលប្រតិស្ឋានទុកនៅទីនេះ គឺពិតជាដំណាងទង់ដែលផុស នោះឯង ។ ចាប់ពីពេលនោះរហូតមកទីកន្លែងនេះ បានក្លាយទៅជាកន្លែងធ្វើ ពិធីបួងសួង បន់ស្រន់សុំសុខចំរើនរបស់ប្រជាជនរៀងរាល់ថ្ងៃ ពិសេសនៅ ថ្ងៃសីលព្រោះគេជឿថា ជាវត្ថុ សក្តិសិទ្ធជួយរំដោះទុកភ័យគេបាន ។

---

« ១ » ពាក្យថា « ដងកើ »

- វចនានុក្រមខ្មែរ ពាក្យ «កើ» ភាសាវៀតណាមប្រែថា «ទង់» ដងកើគឺដងទង់ ។

- មជ្ឈដ្ឋានខ្លះនិយាយថា ពាក្យ « កើ » នេះគឺប្រហែលជាពាក្យខ្មែរពីដើមសរសេរ មាន « រ » គឺ « ដងកើរ » គ្រាន់តែមានសូរស័ព្ទដូចពាក្យវៀតណាម ឬតាមភាសាអ្នកស្រុក យើងនិយាយថា « កើល » មានន័យថាធ្វើអោយទាល់ ធ្វើអោយខ្ពស់ផុត « កើលឬមើស » ។ ដងកើរ គឺដងទង់ដែលផុតខ្ពស់មេឃ គឺកើលនឹងមេឃ ។

- មជ្ឈដ្ឋានខ្លះនិយាយថា ដងកើនេះឈ្មោះពិតប្រាកដដំបូងបំផុតគឺ ដងកល្ប គឺជា ដងទង់ព្រះរាជសង្ការ ជានិមិត្តរូបនៃការកំណត់រជ្ជកាលរបស់ព្រះមហាក្សត្រ ។ កល្ប ភាសា សំស្ក្រឹតក្លាយពីភាសាបាលីថា កប្ប ប្រែ ថាកាលដែលតាំងនៅយូរអង្វែង ។ ដោយសារនៅទីនេះ មានកំពុងផែដ៏ធំមួយ ជាទីប្រជុំចុះនៃមហាជនគ្រប់សាសន៍ខ្មែរ ចិន វៀតណាម ចាម ប្រកបរ អាជីវកម្មការឆ្លងទៅឆ្លងមក រវាងភាសានៃជនជាតិមួយ ទៅជនជាតិមួយ តែងតែមានជៀសមិន ផុត ។ វៀតណាមអានពាក្យកល្បមិនច្បាស់ ទៅជាអានថាកើ ស្របនឹងពាក្យវៀតណាមកើប្រែថា ទង់បានជាបណ្តើរ ១ បាត់ពាក្យដងកល្ប ក្លាយជាពាក្យដងកើ រហូតដល់សព្វថ្ងៃ ។

ក្រោយមកទង់ដែលបង្ហូតនៅដងកល្បនេះពុំមែនជាទង់ក្របីដែលផុសនោះទេ គឺជា ទង់ព្រះរាជសង្ការ ។ ទង់នេះគេបង្ហូតនៅពេលណាព្រះមហាក្សត្រគង់នៅ ។ បើអវត្តមានព្រះមហា ក្សត្រគេមិនដែលបង្ហូតទង់នេះទេ ។ ទង់នេះ អាចបង្ហូតពាក់កណ្តាលសំរាប់តែព្រះមហាក្សត្រ សោយទីវង្គតប៉ុណ្ណោះ មិនអាចបង្ហូតកាន់មរណទុក្ខសំរាប់ថ្នាក់ដឹកនាំដទៃណាបានឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយដែលបានស្ដាបនាដងទង់រួចហើយ ចាស់ទុំទាំងឡាយក៏នាំគ្នាធ្វើស្តូបពីរនៅទីនោះទៀត ដើម្បីឧទ្ទិសចំពោះអ្នកមានឫទ្ធិទាំង ៤ គឺ :

១. ព្រះអង្គដងកើ

២. ព្រះអង្គទសបារមី

៣. ព្រះអង្គកងចក្រ

៤. យាយទេព

*ព្រះអង្គដងកើ ឬ ដងទង់* : ជាវត្ថុសក្តិសិទ្ធិទី ១ មានឫទ្ធិតេជះណាស់ មាននាទីថែរក្សាការពារ ឃុំគ្រងប្រជានុរាស្ត្រ មើលសុខទុក្ខប្រជានុរាស្ត្រ និងជួយសង្គ្រោះរាល់វិបត្តិផ្លូវចិត្តរបស់ប្រជាជន ។ អ្នកដែលមានជម្ងឺឬជួបប្រទះគ្រោះថ្នាក់ផ្លូវកាយ - ចិត្ត តែងនាំគ្នាទៅបន់ស្រន់បួងសួង អោយព្រះអង្គដងកើជួយសង្គ្រោះ ។

*ព្រះអង្គទសបារមី* : វត្ថុសក្តិសិទ្ធិទី ២ មាននាទីថែរក្សាឃុំគ្រងព្រះបរមរាជវាំង ។

*ព្រះអង្គកងចក្រ* : វត្ថុសក្តិសិទ្ធិទី ៣ តំណាងកងទ័ពទាំងបីប្រភេទ មាននាទីជាមេទ័ព ការពារប្រទេសជាតិ និងប្រជាជន ប្រឆាំងនិងខ្មាំងសត្រូវគ្រប់ទិសទី ដែលមានបំណងចង់មកយាយីប្រទេសកម្ពុជា និងប្រជាជន ។ ព្រះអង្គកងចក្រមានឥទ្ធិពលឫទ្ធានុភាពខ្លាំង ទុកដូចជាមេទ័ពត្រួតត្រាលើអ្នកតាទាំងអស់នៅក្នុងទូទាំងប្រទេស ។ ព្រោះហេតុនេះហើយបានជាពេលបែអ្នកតាចិនម្តង ៗ គេតែងឃើញអ្នកតាទាំងនោះមកសំដែងគារវកិច្ចចំពោះព្រះអង្គកងចក្រជានិច្ចនៅមុខវាំង មុននិងបន្តដង្ហែទៅទីផ្សេងទៀត ។

*លោកយាយទេព* : វត្ថុសក្តិសិទ្ធិទី ៤ មាននាទីជាអ្នកជួយសង្គ្រោះប្រជាជន ។ ពិសេសជាអ្នកជំនួយការយ៉ាងសំខាន់ដល់ព្រះអង្គទាំងបីខាងលើ



www.budinst.gov.kh www.elibraryofcambodia.org

លោកយាយមានបរិវារ ៣ នាក់គឺ ៖

១ . ស្រីម៉ៅ

២ . កន្ទោងខៀវ

៣ . ស្រីពៅ

បរិវារទាំងបីនេះមានការងារផ្សេង ។ គ្នាជំនួយការអោយលោកយាយទេព ។

អាស្រ័យដោយអ្នកមានឫទ្ធិទាំង៤ មានឥទ្ធិពលយ៉ាងនេះឯងទើបប្រជាជនយើងមានជំនឿ ហើយបាននាំគ្នាសាងសង់ស្តូបទាំងពីរទុកជាអាស្រមរបស់អ្នកមានឫទ្ធិទាំងនោះ ស្នាក់នៅត្រង់មុខវាំងរហូតមក ។ ដើមឡើយ អាស្រមទាំងពីរមិនមានលក្ខណៈប្រណីតដូចសព្វថ្ងៃនេះទេ ។ តែក្រោយមកដោយផ្អែកលើការរីកចំរើនរបស់ទីក្រុង គេក៏សាងសង់អាស្រមទាំងពីរនេះអំពីថ្ម ។ អាស្រមខាងជើងជាអាស្រមរបស់លោកយាយទេព និងបរិវារ ឯអាស្រមខាងត្បូងជាអាស្រមរបស់ព្រះអង្គដងកើស្នាក់នៅទាំងបីព្រះអង្គ ។ អាស្រមខាងត្បូងមានតម្កល់រូបលោកេស្វរៈ ឈរមានដៃ៨ទ្រង់គ្រឿង តែអាស្រមខាងជើងពុំមានឃើញរូបសំណាកអ្វីទេ ។

**ប្រភពពាក្យមានទី ២** ៖ បានពីលោក យី ធន់ « ក្រសួងឃោសនាការវប្បធម៌ » លោកបានឲ្យចាស់ ។ ដំណាលប្រាប់លោកថា ៖

ក្នុងកាលដ៏យូរលង់នៅមុខវាំងនេះ មានតែទីត្រង់ដងកើនេះទេដែលជាទីទួល ដ៏មានព្រៃពោធិ៍ត្រឈើងត្រឈៃ ដុះប្របររបនឹងផងដៃទន្លេសាប ។ ទីនេះមានចំណតផែដ៏ធំដែលមនុស្សម្នា មហាជនអ្នកលក់ដូរខ្មែរ ចិន យួន តែងចេញ ចូលទៅមកប្រកបអាជីវកម្មប្រចាំថ្ងៃ ។ គេជឿនិងទទួលស្គាល់ថាត្រង់ទួលព្រៃត្រឈើងត្រឈៃនេះ មានវត្ថុសក្តិសិទ្ធិណា



www.budinst.gov.kh www.elibraryofcambodia.org

មួយអាចយកជាទីពឹងជួយសង្គ្រោះចំពោះរូបគេបាន ។ ព្រោះហេតុនេះហើយ បានជាមុនពេលចេញដំណើរទៅរកស៊ីលក់ដូរ ឬទៅប្រកបការងារអ្វីមួយ គេតែងបួងសួងសុំបួងសួងបន់ស្រន់ចំពោះអស់លោកអ្នកមានឫទ្ធិចេស្តាត្រង់កន្លែងចំណោតផែនេះ ដើម្បីសុំសុខចំរើនជោគជ័យ ។ តាមរឿងដំណាលថា នៅពេលយប់ជារៀងរាល់យប់ គេតែងឃើញមានដុំភ្លើងហោះពីទិព្រៃនៅត្រង់ផងកេិ ទៅកប់បាត់ទៅក្នុងវាំង ហោះចេញពីក្នុងវាំងមកកប់បាត់នៅត្រង់ព្រៃផងកើនេះ ។ ដុំភ្លើងនោះមានពណ៌សក៏មាន ខៀវក៏មានចំរុះពណ៌ស ខៀវក៏មាន ហោះធ្លោចុះធ្លោឡើងទៅមក ៗ ។ អ្នកបានឃើញដុំភ្លើងហោះនោះតែងតែព្រឺក្បាល ព្រឺស្បែកគ្រប់ ៗ គ្នា ។ ចាស់ទុំជំនាន់នោះគេសំគាល់ថា ដុំភ្លើងនោះជាតំណាងវត្ថុសក្តិសិទ្ធិអ្វីមួយ ហើយមានទីលំនៅពិតប្រាកដនៅត្រង់ព្រៃឈើត្រង់ទួលផងកើនោះឯង ។ ម្ល៉ោះហើយគេក៏នាំគ្នាកសាងជាអាស្រមនៅត្រង់ផងកើនេះ ទុកជាលំនៅឋានដ៏សមរម្យជូនអស់លោកអ្នកមានឥទ្ធិពល មានមហិទ្ធិរិទ្ធិ ដើម្បីងាយស្រួលដល់ការធ្វើពលិការផ្សេង ៗ របស់ប្រជាជនអ្នកមានជំនឿ ។

តំណពីនោះមក កន្លែងផងកើនេះក្លាយទៅជាកន្លែងបួងសួងសុំបួងសួងបន់ស្រន់ ដ៏សក្តិសិទ្ធិរបស់ប្រជាជនខ្មែរអ្នកមានជំនឿ ។ មិនតែប៉ុណ្ណោះ កងទ័ពខ្មែរដែលមានឥទ្ធិពលល្បីល្បាញ ក្នុងការធ្វើសឹកសង្គ្រាមជ័យមិនដែលចាញ់ខ្មាំងសត្រូវ ទាំងទ័ពជើងទឹក ទ័ពជើងគោក មុនចេញទៅធ្វើសឹកសង្គ្រាមកំចាត់មារសត្រូវការពារមាតុភូមិ ការពារប្រជាជន ក៏សុទ្ធតែធ្វើពិធីបួងសួងបន់ស្រន់សុំពរជ័យឫទ្ធិចេស្តាបារមី នៅត្រង់ផងកើនេះមិនដែលលោះខាន ។ ក្រោយពីពិធី បួងសួងសុំពរជ័យហើយគេស្រែកជ័យឃោសន៍ពន្រឹកភាពស្វាហាប់ ក្លាហានទ្រហឹងអឹងកង ទើបចេញដំណើរ



www.budinst.gov.kh www.elibraryofcambodia.org

ហើយតែងជណ្តើមបានជាញជ័យក្នុងសឹកសង្គ្រាម ។

រីឯ កប៉ាល់ កាណូត មុនចេញដំណើរទៅក្រៅ និងមុនចូលដល់ចំណតផែនៅភ្នំពេញ កាលណាបើកមកដល់មុខដងកើ ដាច់ខាតត្រូវស៊ីផ្លែ ៣ ដង ជាសញ្ញានៃការគោរពសុំពរជ័យសុខចំរើនពីព្រះអង្គដងកើ ។ ប្រជាជនអ្នកមានជំនឿ មានវិបត្តិក្នុងគ្រួសារ និងផ្ទាល់ខ្លួន ឬក៏មានភយន្តរាយណាមួយមកគ្របសង្កត់ ក៏តែងតែបួងសួងបន់ស្រន់សូមអោយព្រះអង្គដងកើជួយសង្គ្រោះ ។ ជំនឿនេះ បានដក់ជិតជាប់រហូតមកដល់សព្វថ្ងៃ ។

លោក យី ធន់ បានអោយដឹងថា ចំពោះប្រវត្តិស្តូបព្រះអង្គដងកើនេះ បើតាមចាស់ ៗ ដែលធ្លាប់រស់នៅទីនេះនិយាយដំណាលអោយដឹងថា ស្តូបនេះប្រហែលជាកសាងឡើង ក្រោយពេលកសាងព្រះរាជវាំងចតុម្មុខសព្វថ្ងៃនេះ គឺនៅដើមសតវត្សទី ២០ ។ ឯដងកើ « ដងទង់ » គេសង់ជាខាងក្រោយទេ សំរាប់បង្ហូតទង់របស់ព្រះមហាក្សត្រនៅមុខវាំង គឺទង់ព្រះរាជសង្ហារ ។ រីឯផ្លូវដែលចេញពីវាំងត្រង់ទ្វារចំកណ្តាលឆ្ពោះទៅមាត់ទន្លេ ជាផ្លូវសំរាប់ស្តេចយាងចុះកំពង់ផែ ដើម្បីធ្វើដំណើរទៅ ខេត្ត - ខ័ណ្ឌ ដែលនៅជាប់នឹងមាត់ទន្លេនិងយាងទៅក្រុងព្រៃនគរ ពីមុនផ្លូវនេះឈ្មោះផ្លូវ « ប្រជាប់ក្រុង» ។ ជំនាន់នោះមិនទាន់មានផ្លូវគោកសំរាប់ទៅក្រុងព្រៃនគរទេ ។ ដូច្នេះការធ្វើដំណើរតាមផ្លូវទឹក អាចមានភ័យអាសន្នដោយមានព្យុះខ្យល់នៅផ្លូវឆ្ងាយ បានជាមុននឹងចេញដំណើរ គេតែងតែបន់ស្រន់សុំពរជ័យពីទសបារមីវាំង និងព្រះអង្គដងកើនេះ សុំអោយគេធ្វើដំណើរបានសុខសប្បាយ ។ ម្យ៉ាងទៀតនៅពេលគេជួបគ្រោះអាសន្នក្នុងពេលធ្វើដំណើរ ក៏គេបន់ស្រន់ចំពោះព្រះអង្គដងកើដែរ ។

នៅក្នុងដំណើររបស់សម្តេច នរោត្តម ទៅទស្សនាក្រុងហុងកុង



www.budinst.gov.kh www.elibraryofcambodia.org

និង ហ្វីលីពីន កាលពីឆ្នាំ ១៩៧២ មានប៉ះព្យុះសមុទ្រយ៉ាងធំ ព្រះអង្គក៏បានធ្វើការបន់ស្រន់ដែរ ។ ប៉ុន្តែនៅក្នុងឯកសារមិនឃើញមានថែងពីអ្នកកសាងស្តូបទាំងពីរនេះទេ ។ ស្តូបនេះទំនងជាស្នាដៃរបស់ប្រជាជនអ្នកមានជំនឿទៅលើវត្ថុសក្តិសិទ្ធិនៅត្រង់កន្លែងនេះ ។

រហូតមកដល់សព្វថ្ងៃនេះក្តី ក៏ប្រជាជនដែលធ្វើដំណើរទាំងតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ក៏តែងតែបន់ស្រន់ព្រះអង្គដងកើនៅពេលគេជួបគ្រោះអាសន្នដែរ ។ ក្រៅពីនេះ អ្នកមានភ័យអាសន្នក្នុងគ្រួសារដូចជាមានជំងឺប្រកបថ្នាំមិនត្រូវ ពេលសំរាលកូនពិបាក ពេលមានបាត់របស់រកមិនឃើញ . . . . ល . . . . ក៏នាំគ្នាបន់ស្រន់ព្រះអង្គអោយជួយដែរ ។ ទាំងនេះមកពីប្រជាជនមានជំនឿថា ព្រះអង្គដងកើនេះជាវត្ថុសក្តិសិទ្ធិ អាចជួយទុក្ខធុរៈរបស់គេបានដរាបរៀងមក ។

ប៉ុន្តែទីអាស្រម ដែលជាទីតម្កល់វត្ថុសក្តិសិទ្ធិនេះ ត្រូវទទួលរងមហន្តរាយក្នុងឆ្នាំ ១៩៧៥ - ១៩៧៨ ដោយសាររបបកម្ពុជាប្រជាធិបតេយ្យបំផ្លិចបំផ្លាញ ។

**ប្រភពពាក្យមានទី ៣** : បានពីលោក ប៊ូ សៅ ប្រធានវិហារព្រះកែវមរកត លោក ប៊ូ សៅ បាននិទានប្រាប់ថា ដើមឡើយនៅខាងកើតដងកើនេះ មានកំពង់ផែមួយដ៏ធំ ជាទីចេញចូលធ្វើដំណើរពីភ្នំពេញ ទៅខេត្ត - ខ័ណ្ឌជាប់ដងទន្លេ និងពីខេត្ត - ខ័ណ្ឌជាប់ដងទន្លេ មកភ្នំពេញរបស់មនុស្សម្នា មហាជនគ្រប់ស្រទាប់ក្នុងបេសកម្មបំរើការងាររាជការ និងការប្រកបរបរអាជីវកម្មផ្សេង ៗ ។

ដើម្បីងាយស្រួលក្នុងការថែរក្សា ដាក់សម្ភារៈទំនិញគ្រឿងឧបភោគបរិភោគ ដែលត្រូវចុះឡើង ទូក កាណូត កប៉ាល់ផង និង



www.budinst.gov.kh www.elibraryofcambodia.org

ដោយទីនេះជាប្រភពដីល្បាប់មានជីជាតិ ផ្តល់ទិន្នផលច្រើនក្នុងវិស័យកសិកម្មដាំដុះផង គេទាំងឡាយក៏បានសាងសង់ជាផ្ទះតូច ៗ នៅក្បែរកំពង់ផែនោះ ។ ចំណេរតមក ដោយជីវភាពចេះតែមានការីកចំរើន ប្រជាជននៅទីនេះ ក៏នាំគ្នាសាងសង់ជាផ្ទះធំទ្រនំខ្ពស់ជាបន្តបន្ទាប់ កកើតទៅជាភូមិមួយឈ្មោះថា « ភូមិកំពង់ផែ » ។ ភូមិកំពង់ផែនេះ ជាភូមិកំណើតរបស់ព្រះមហាវិមលធម៌ « ថោង » ចាងហ្វាងសាលាបាលីជាន់ខ្ពស់ជំនាន់ ទី១ ។ ប៉ុន្តែអាស្រ័យដោយទឹកជំនន់ ច្រាំងទន្លេច្រោះបាក់ជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ទើបភូមិកំពង់ផែត្រូវរលាយបាត់ឈ្មោះ ។ ឯអ្នកភូមិកំពង់ផែទាំងប៉ុន្មាន ក៏ទៅរកទីលំនៅផ្សេង ៗ តាមការចូលចិត្តរៀង ៗ ខ្លួន ។ រីឯដងកើ និងវិហារទាំងពីរក៏ចេះតែរំកិលតាមច្រាំងទន្លេបាក់ ហើយក៏បានមកប្រតិស្ឋានស្ថិតនៅកន្លែងសព្វថ្ងៃនេះ ។

លោក ប៊ូ សៅ បានអោយដឹងថា វិហារតូចពីរនៅត្រង់ព្រះអង្គដងកើ ដែលត្រូវគេបំផ្លិចបំផ្លាញចោលក្នុងអំឡុងឆ្នាំ ១៩៧៥ - ១៩៧៨ នោះកសាងឡើងទន្ទឹមនឹងការកសាងប្រាសាទទេវាភោជនីយ, ប្រាសាទចន្ទឆាយាប្រាសាទ សិរីទ្ធិវិមានសម្រាន្តភិរម្យ ក្នុងរជ្ជកាល សម្តេចព្រះបាទព្រះ ស៊ីសុវត្ថិ នាឆ្នាំ ១៩១៣ ។ តែពុំដឹងថា អ្នកណាជាអ្នកកសាងទេ ។ ប្រហែលជាស្នាដៃអ្នកមានជំនឿតាមព្រហ្មញ្ញសាសនា ។ វិហារខាងត្បូងមានឃើញតម្កល់រូប លោកេស្វរៈ ដៃ ៨ ទ្រង់ឈរ ។ ឯវិហារខាងជើងពុំឃើញរូបសំណាក អ្វីទេ ។ ក្រោយមកលោកឃើញមានដាក់សម្ភារៈ ឧកញ៉ាពិភក្តិ ភេត្រា នាយផ្នែកនាវាចរណ៍ព្រះរាជទ្រព្យ ។

លោក ប៊ូ សៅ បានសន្និដ្ឋានថា ចំណែកដងទង់ ឬ ដងកើនេះប្រហែលជាកកើតឡើងដំណាលគ្នានឹងវិហារទាំងពីរនេះដែរ តែពុំឃើញ



www.budinst.gov.kh www.elibraryofcambodia.org

មានសេសសល់ឯកសារណាមួយ បញ្ជាក់ពីការបរិច្ឆេទពិតប្រាកដទេ ។

ចំពោះការបង្កួតទង់ឬដាក់ទង់ព្រះរាជសង្ហារនេះ គឺប្រារព្ធឡើងក្នុងរូបភាពចាត់តាំងមួយក្រិត្យក្រមណាស់ ដោយមានទាហានក្រុមព្រះរាជទ្រព្យ គំនាប់ គោរព កាន់ទ្រយ៉ាងហ្មត់ចត់ ។

**ប្រភពពត៌មានទី ៤** ៖ បានពីលោក ប៉ុល - លឹម លេខាធិការផ្ទាល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

លោក ប៉ុល - លឹម បាននិយាយប្រាប់ថា កាលនៅពីកុមារ លោកតែងតែទៅងូតទឹកនៅជិតរោងជិរីមុខរដ្ឋសភា និង នៅមាត់ទន្លេ ហើយលោកឃើញចាស់ ៗ ព្រឹទ្ធាចារ្យបន់ស្រន់បួងសួងសុំបួសុំរួង នៅស្តូបជាប់ដងគេនេះ ។ ពេលនោះ លោកក៏មានការចាប់អារម្មណ៍ ហើយក៏បានសាកសួរចាស់ ៗ ពីដំណើររឿងនៃការបន់ស្រន់នោះ ។ លោកតាចាស់ ៗ បាននិយាយថា ៖

នៅរជ្ជកាល នៃព្រះមហាក្សត្រគ្រប់គ្រងប្រទេស ដែលបានមកកសាងព្រះបរមរាជវាំងនៅចតុមុខនេះ គេតែងសង្កេតឃើញកើតកលិយុគប្រកបដោយវិបត្តិ វិបរិតផ្សេង ៗ ជាញឹកញាប់នៅចំកណ្តាលទន្លេប្រសប់មុខបួន កើតមានគ្រោះថ្នាក់កាចចង្រៃខ្យល់ព្យុះបក់បោកយ៉ាងខ្លាំងអស្ចារ្យបណ្តាលអោយកប៉ាល់ កាណូត ទូកលិចលង់ និង បាត់បង់ជីវិតមនុស្សជាច្រើននាក់យ៉ាងសែនរន្ធត់ចិត្តបំផុត ។ ជួនកាលខ្លះគេឃើញស្រមោលស្តុង ៗ ហាក់ដូចជាកប៉ាល់រៀបនឹងលិចទឹក ដោយថែមទាំងឮសូរសំឡេងមនុស្សស្រែកខ្សៀវខ្សាជ្រួលច្របល់ ដង្ហើយហៅរកអោយគេជួយយករាសារទៀតផង ។ ក្រៅពីគ្រោះថ្នាក់កាចសាហាវ នៅកណ្តាលលំហទន្លេប្រសប់មុខបួននោះ ក៏នៅមានកើតមហន្តរាយផ្សេង ៗ ទៀតដែរក្នុងព្រះនគរ ។



www.budinst.gov.kh www.elibraryofcambodia.org

ដោយសារតែមានបាតុភូតគ្រោះកាចចង្រៃ នៅចំមុខវាំងយ៉ាងដូច្នេះ ទើបហ្លួងទ្រង់ត្រាស់ព្រះរាជបញ្ជាហៅរកហោរាអោយទស្សន៍ទាយព្យាករណ៍មើលពីវិភេទនគរកម្ពុជា តើយ៉ាងម៉េច ? ។ នាពេលនោះ ហោរាទស្សន៍ទាយព្យាករណ៍ថា : បពិត្រព្រះមហាក្សត្រ សូមព្រះអង្គទ្រង់ជ្រាបថា : ការកសាងព្រះបរមរាជវាំងនៅចតុមុខនេះល្អប្រសើរបំផុត និងរុងរឿងទៀតផង ។ ចំណែកឯការកើតកលិយុគគ្រោះកាចចង្រៃ នៅចំកណ្ដាលទន្លេប្រសប់មុខប្អូននោះ សូមព្រះអង្គចេញទៅបន់ស្រន់បួងសួង សុំសេចក្ដីសុខទៅ មុខជាបានសំរេចហើយ ។ ទើបព្រះមហាក្សត្រសព្វព្រះរាជហឫទ័យទ្រង់ត្រាស់បង្គាប់អោយរៀបចំធ្វើស្ដូបបន់ស្រន់នៅមុខវាំងនេះ ព្រមទាំងអោយសាងសង់ដងគោមភ្លើងមួយខ្ពស់ត្រដែត ត្រដឹម ជាសញ្ញាសំគាល់ថាហ្លួងម្ចាស់ជីវិតបានធ្វើកន្លែងបន់ស្រន់ និង អុចភ្លើងបំភ្លឺលើដងគោមនោះជានិច្ចកាលហើយ ។ ម៉្យាងទៀតសំរាប់បង្ហាញមនុស្សម្នាផងទាំងឡាយដែលធ្វើដំណើរតាមទន្លេមកដល់កន្លែងនេះ ដឹងថាដល់ព្រះបរមរាជវាំងរបស់នគរកម្ពុជា ។ ដូច្នេះស្ដូប និងដងទង់ ឬដងគោមនេះ ក៏ក្លាយទៅជាទីសក្ការៈបូជារបស់ព្រះមហាក្សត្រគ្រប់គ្រងប្រទេស និងព្រះរាជវង្សានុវង្ស ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រី និងប្រជារាស្ត្រ តែងមានជំនឿគោរពបូជា ត ៗ គ្នាមកហើយដងទង់ឬដងគោមនេះ ក៏ក្លាយឈ្មោះជាដងកើ រហូតដល់សព្វថ្ងៃនេះ និង មានមហិទ្ធិរិទ្ធិគួរជាទីស្ញប់ស្ញែង ត្រូវតែគោរពខានពុំបាន ទោះជាចេញដំណើរទៅទីណា ៗ ក៏ដោយ ឬអោយតែដើរជិត ឬឆ្លងកាត់ដងកើនេះតែងតែបន់ស្រន់សុំសេចក្ដីសុខជាប់ជានិច្ច ។

លោក ប៉ុល - លីម បានអោយដឹងថា ដងកើនេះកើតក្រោយកំណើតព្រះបរមរាជវាំង ។ ឯការបន់ស្រន់បួងសួងនៅទីនេះ គឺមានជាប់



www.budinst.gov.kh www.elibraryofcambodia.org

ជាតំណាងនៃរបាំមហាក្សត្រខ្មែរ តាំងពីព្រះបាទសម្តេចព្រះនរោត្តមមក ។

រីឯការបន់ស្រន់នៅត្រង់ដងកើនេះ លោក ប៉ុល - លីម បាន បញ្ជាក់ថា គេបន់ស្រន់នឹកដល់គុណបុណ្យព្រះអង្គទសបារមី ដែលមាន មហិទ្ធិរិទ្ធិ ៤ ព្រះអង្គអោយជួយសហការថែរក្សាគឺ :

១ - ទសបារមីព្រះអង្គដងកើ

២ - ទសបារមីព្រះអង្គព្រះវិហារសួគ៌

៣ - ទសបារមីព្រះអង្គព្រះកែវមរកត

៤ - ទសបារមីព្រះអង្គព្រះពិស្ណុការ

* ទសបារមីព្រះអង្គដងកើ មានទីតាំងសណ្ឋិតនៅជានិច្ចកាល នៅ មុខព្រះបរមរាជវាំង ទល់នឹងទន្លេចតុមុខ ។

* ទសបារមីព្រះអង្គព្រះវិហារសួគ៌ មានទីតាំងនៅវត្តវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានមុខសញ្ញាគ្រប់គ្រងថែរក្សា ផ្នែកខាងកើតទន្លេមេគង្គ ។

* ទសបារមីព្រះអង្គព្រះកែវមរកត មានទីតាំងនៅក្នុងព្រះវិហារ ព្រះកែវមរកត មានមុខសញ្ញាថែរក្សាគ្រប់ទិសទីក្នុងព្រះបរមរាជវាំង មាន តេជះបារមីខ្លាំងណាស់ ពិសេសចំពោះអ្នកធ្វើដំណើរតាមផ្លូវទឹក ព្រោះព្រះ អង្គព្រះកែវមរកតមានរឿងដំណាលថា ជាព្រះអង្គមានមហិទ្ធិរិទ្ធិសំបើម អស្ចារ្យ នៅពេលដែលសំពៅត្រូវខ្យល់ព្យុះបោកបក់បណ្តាលអោយលិចនា ក្នុងមហាសាគរដ៏ធំធេងនោះ រូបព្រះអង្គព្រះកែវមរកតនោះ បានអណ្តែត ប្រាសទឹកទៅទើរនៅលើកោះគោកធ្លក ។

* ទសបារមីព្រះអង្គព្រះពិស្ណុការ មានទីតាំងនៅប្រាសាទអង្គរវត្ត នាខេត្តសៀមរាប មានឥទ្ធិពលខ្លាំងណាស់ មានមុខសញ្ញាថែរក្សាកេរ



www.budinst.gov.kh www.elibraryofcambodia.org

ដំណែលជូនតានៅក្នុងព្រះនគរទាំងមូល ។

ខ្លឹមសារនៃការបន់ស្រន់ គឺ :

១ - សុំអោយទន្លេចតុមុខ ដែលជាទីប្រជុំចុះនៃទឹកហូរប្រសប់មុខ ដ៏ធំល្វឹងល្វើយខ្វលខ្វាញ់ មានកំលាំងខ្លាំង ឈប់បក់គួចកប៉ាល់ កាណូតទូកក្ដារ បង្កអោយមានឧទកភ័យ ធ្វើអោយមនុស្សម្នា មហាជនគ្រោះថ្នាក់ ខូចខាតទ្រព្យសម្បត្តិ និងបាត់បង់ជីវិតតទៅ ។

- សុំអោយច្រាំងទន្លេខាងលិចជាប់ នឹងរាំងឈប់ច្រោះបាក់

- សុំអោយដីកោះជ្រោយចង្វារ ឆាប់ដុះជាកោះអោយបានធំវែងរហ័ស ដើម្បីជួយទប់ទឹកទន្លេបួនមុខ កុំអោយហូរបុកខ្លាំងបណ្ដាលអោយមានគ្រោះថ្នាក់ ។

- សុំអោយក្នុងព្រះបរមរាជវាំង និងក្នុងព្រះនគរទាំងមូល ជៀសផុតពីកោលាហល កលិយុគ ឬវិបត្តិអន្តរាយ ។

- សុំអោយផ្ដល់នូវជោគជតារាសី ក្ដីសុខក្សេមក្សាន្ត សុភមង្គលវិបុលសុខ សំបូររុងរឿងតរៀងទៅ ។

២ - សុំអោយព្រះបរមរាជវាំង និងនគរកម្ពុជាមានតេជះបារមីរិទ្ធិចេស្ដា ទាក់ទាញអោយប្រទេសទាំងឡាយលើសកលលោក ខ្លបខ្លាចកោតស្ញប់ស្ញែង ។

លោក ប៉ុល - លឹម ដំណាលប្រាប់បន្ថែមទៀតថា ក្រោយមកក្នុងរជ្ជកាលព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិ មុនីវង្ស នៅភ្នំពេញមានកើតឧប្បហេតុមួយយ៉ាងអស្ចារ្យក្នុងពេលដែលអ្នកអង្គម្ចាស់នរោត្ដមច័ន្ទ<u>លេខា</u> ហៅតូ ត្រូវនិរទេសចេញក្រៅនគរនោះ គឺមានភ្លៀងធ្លាក់ ៧ យប់ ៧ ថ្ងៃ រន្ទះបាញ់ត្រូវដងកើនោះបាក់ជាពីរ ។ រីឯព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិ មុនីវង្ស មានអាពាធ



www.budinst.gov.kh www.elibraryofcambodia.org

ហើមព្រះនេត្រទាំងសងខាង ឈឺពើតផ្សារយ៉ាងក្រៃលែង ទើបព្រះអង្គទ្រង់ត្រាស់បង្គាប់អោយហោរាទស្សន៍ទាយព្យាករណ៍មើល តើក្នុងនគរកើតវិភេទអ្វី ហើយព្រះអង្គវិញមានអាពាធខុសប្លែកធម្មតា ។ នាពេលនោះហោរាទស្សន៍ទាយថា ត្រូវយាងអ្នកអង្គម្ចាស់ច័ន្ទលេខា ហោរ៉ត្នូ វិលចូលនគរវិញ ទើបភ្លៀងរាំង ហើយព្រះនេត្ររបស់ព្រះអង្គ ស្រកជាសះស្បើយដូចដើមវិញ ព្រោះតាមជើងលេខថា អ្នកអង្គម្ចាស់ច័ន្ទលេខា មានមហិទ្ធិ រិទ្ធិពូកែខ្លាំងណាស់ ហើយវិជ្ជាវេទមន្តវិញពូកែទៀតផង អ្នកអង្គម្ចាស់បានបន់ស្រន់នៅពេលចេញដំណើរទៅថា សូមព្រះអង្គទសបារមីទាំងប្អូនតាមជួយថែរក្សាព្រះអង្គផង និងសូមអោយហ្លួងយាងព្រះអង្គចូលនគរវិញ បើមិនយាងចូលវិញទេនោះ ព្រះអង្គនៅតែកើតក្តីភិតភ័យជាប់ជានិច្ច ហើយមានអាពាធប្រចាំព្រះកាយទៀតផង ។

តមកព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ មុនីវង្ស បានទ្រង់ត្រាស់អោយកសាងជងកើនេះឡើងវិញ ដោយព្រមយាងអ្នកអង្គម្ចាស់នរោត្តមច័ន្ទលេខា ហោរ៉ត្នូ អោយចូលនគរវិញ ហើយរៀបចំធ្វើបុណ្យបន់ស្រន់បួងសួង ៣ ថ្ងៃ ៣ យប់ នៅត្រង់ព្រះអង្គជងកើនេះ ។

តាំងពីនោះមក ទាំងព្រះមហាក្សត្រគ្រប់គ្រងប្រទេស ទាំងព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី អ្នករាជការផងទាំងឡាយ និងប្រជារាស្ត្រ តែងមានជំនឿជឿ និង បន់ស្រន់នឹកគុណដល់ព្រះអង្គទសបារមីទាំងប្អូនោះជាប់ជានិច្ច ពិសេសកន្លែងត្រង់ព្រះអង្គជងកើ និងស្តូបនៅទីនោះត្រូវបានគោរពបូជារហូតដល់សព្វថ្ងៃនេះ ។


www.budinst.gov.kh www.elibraryofcambodia.org

## ការសន្និដ្ឋានរបស់អ្នកនិពន្ធ :

ផ្អែកលើជំនឿរបស់ប្រជាជនខ្មែរ យើងខ្ញុំអ្នកស្រាវជ្រាវ សូមធ្វើសេចក្ដីសន្និដ្ឋានដូចតទៅនេះ :

ពតិមានដែលយើងខ្ញុំទទួលបានមានចំណុចខ្លះ អាចយកជាប្រភពដែលនាំអោយកើតព្រះអង្គដងកើនេះ ព្រោះថា :

តាមប្រវត្តិសាសនា ដែលមាននៅកម្ពុជា ហើយដែលខ្មែរភាគច្រើនបានគោរពបូជា គឺមានព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា សម័យខ្លះព្រះរាជាកាន់ព្រហ្មញ្ញសាសនា នាម៉ឺនសព្វមុខមន្ត្រី និងប្រជារាស្ត្រកាន់ព្រះពុទ្ធសាសនា ពេលសម័យខ្លះ ព្រះរាជាកាន់ព្រះពុទ្ធសាសនា នាម៉ឺនសព្វមុខមន្ត្រីប្រជារាស្ត្រកាន់ព្រហ្មញ្ញសាសនាផង និង ពុទ្ធសាសនាផង ។ ជាក់ស្ដែង ចាប់ពីពុទ្ធសតវត្សទី ១៤ និង គ្រិស្តសតវត្សទី ៩ មក ពុទ្ធសាសនាថេរវាទ « ហីនយាន » ក្ដី ពុទ្ធសាសនា អាចរិយវាទ « មហាយាន » ក្ដី ព្រហ្មញាសាសនាក្ដីមាននិន្នាការផ្លាស់ប្ដូរប្រែប្រួលជាបន្តបន្ទាប់ ឧទាហរណ៍ ព . ស ១៣៤៥ គ.ស ៨០២ , ព្រះរាជាកាន់ព្រហ្មញ្ញសាសនា នាម៉ឺនមុខមន្ត្រី និង ប្រជារាស្ត្រគោរព ព្រះពុទ្ធសាសនា . . . ល . ។

ហេតុនេះជំនឿចំពោះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាបានដក់ជាប់ក្នុងផ្នត់គំនិតរបស់ប្រជាជនខ្មែរគ្រប់រូប ច្របូកច្របល់លាយឡំគ្នានៅក្នុងពិធីកម្មសាសនារហូតដល់សព្វថ្ងៃ ។

- ពិនិត្យលើរូបសំណាកដែលតម្កល់នៅក្នុងវិហារក្បែរដងកើ គឺពុំមែនជារូបព្រះពុទ្ធបដិមាករ គឺជារូបលោកេស្វរៈ មានដៃ ៨ ទ្រង់គ្រឿងឈរ ដែលជាតំណាងនៃព្រហ្មញ្ញសាសនា ។



www.budinst.gov.kh www.elibraryofcambodia.org

- រូបភាពនៃពិធីកម្ម ឬ ពលីការផ្សេង ៗ របស់ប្រជាជនយើង ក្នុងពិធីគោរពបូជា ពុំមានលក្ខណៈជាពុទ្ធសាសនាសុទ្ធសាធទេ ដូចជាស្លាធម៌ ដូង - បាយសី - គ្រឿងបូជាផ្សេង ៗ ។

- ឯពិធីសុំសុខចំរើនទៀត គឺការបន់ស្រន់បួងសួងសំបូងសំរូង ដែលពុំមែនជាខ្លឹមសារពុទ្ធសាសនា គឺជាខ្លឹមសារនៃព្រហ្មញ្ញសាសនា ។ រាល់ការបន់ស្រន់សុទ្ធតែផ្សារភ្ជាប់ទៅនឹងជំនួយរបស់អស់លោក អ្នកមានឫទ្ធិបារមី ។

អាស្រ័យហេតុនេះ ប្រភពពតិមានទាំងប៉ុនដែលយើងលើកយកមករៀបរាប់ទីនេះក៏ឃើញថា មានលក្ខណៈសមស្របខ្លះទៅនឹងជំនឿក្នុងព្រហ្មញ្ញសាសនា ដែលប្រជាជនយើងធ្លាប់ជឿកន្លងមក ។

ការស្រាវជ្រាវប៉ុណ្ណេះគ្រាន់តែជាផ្នែកខ្លះ ដែលទទួលបានពីការនិយាយត ៗ គ្នា ។ រីឯការបរិច្ឆេទ ពិតប្រាកដដែលកើតព្រះអង្គដងកើ វិហារទាំងពីរ ក៏មិនឃើញមានសេសសល់ឯកសារណាមួយ ធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវឡើយ ។

សូមអធ្យាស្រ័យពីបណ្ដាមិត្តអ្នកអាន ហើយនឹងសូមជួយបំពេញបន្ថែមនូវអ្វីដែលមិត្តអ្នកអានយល់ថា ត្រឹមត្រូវមានប្រយោជន៍ ដើម្បីបានឯកសាររួមមួយទុកជាអនុស្សាវរីយ៍ក្នុងឱកាសពិធីសម្ពោធ បើកអោយប្រើប្រាស់ជាផ្លូវការវេទិកា និង វិហារទាំងពីរនៅមុខវាំង និង ពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ អកអំបុកឆ្នាំ ១៩៩១ នេះ ។

អ្នកនិពន្ធ

**ជា - តាន**

- សមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិវណ្ណសិល្ប
- អនុប្រធាននាយកដ្ឋានឃោសនាពិកពិន-និពន្ធ
ខុទ្ទកាល័យក្រុមប្រឹក្សាជាតិវណ្ណសិល្ប ,



www.budinst.gov.kh www.elibraryofcambodia.org

# ប្រវត្តិបុណ្យ អុំទូក បណ្ដែតប្រទីប

# សំពះព្រះខែ អកអំបុក

## ប្រភពពិធីបុណ្យ ប្រណាំងទូក

ប្រវត្តិនៃបុណ្យអុំទូក មានតាំងពីបូរមបូរាណដ៏យូរលង់មកហើយ ដែលមានចែងក្នុងឯកសាររបស់ប្រវត្តិវិទូបរទេសក៏ដូចជាតាមសិលាចារិកនៃប្រាសាទអង្គរ ។ សូមបញ្ជាក់ថា បុណ្យអុំទូកនេះមានការបកស្រាយប្លែក ៗ គ្នាជាច្រើន ហើយពិធីធ្វើ ក៏មានប្លែក ៗ គ្នាខ្លះដែរ ។

ក . តាមសៀវភៅជ័យវរ្ម័នទី ៧ មាននៅក្នុងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យយើងពីដើមមានចែងថា ៖

នៅសម័យអង្គរនា គ្រឹះសករាជសតវត្សទី ១២ ក្នុងកម្ពុជា មានសេចក្ដីសុខក្សេមក្សាន្តរុងរឿងណាស់ដោយព្រះបាទជ័យវរ្ម័នទី ៧ ស្ដេចចេញធ្វើសង្គ្រាមជើងទឹក បង្ក្រាបពួកចាមដោយកងទ័ពទូក ជាចំបាំងរំដោះក្រុងកម្ពុជាអោយរួចផុត ស្រឡះចេញពីខ្មាំងសត្រូវ ( គ.ស ១១៧៧-១១៨១ )រឿងចំបាំងគ្រានោះ មានឆ្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន និង បន្ទាយឆ្មារ ។

ក្នុងចម្លាក់នោះឃើញមានកងទ័ពទូកជាច្រើនមហិមា ដែលមានព្រះឆាយាលក្ខណ៍នៃព្រះបាទជ័យវរ្ម័នទី ៧ ប្រថាប់ឈរលើទីតាំងនាវាចំបាំងដោយទ្រង់ធ្នូ និង ដំបងយ៉ាងស្វាហាប់ក្នុងចំនោមកងទ័ពទូកទាំងឡាយ ។

ខ . ឯកសារល្បែងប្រណាំងទូក របស់ក្រុមជំនុំទំនៀមទំលាប់



www.budinst.gov.kh www.elibraryofcambodia.org

លេខ ១៥ . ០០៤ និពន្ធដោយលោកចាច់ ប៉ែន ហៅ ប៉ាង អាចារ្យ នៅពុទ្ធ-សាសនបណ្ឌិត្យរង ខេត្តឃ្លាំង កម្ពុជាក្រោម មានចែងថាៈ

« សម័យលង្វែក ព.ស ២០៧១ គ.ស ១៥២៨ » ព្រះបាទអង្គចន្ទទី ១ ទ្រង់ តាំងពញាតាត ងារជាស្មិទ្ធិភូបាល ជាស្តេចត្រាញ់នៅកម្ពុជាក្រោម ស្រុកបាសាក់ ។ ស្តេចត្រាញ់នេះបានចាត់របៀបរៀបចំ ការពារស្រុកមានដូចតទៅនេះ : /

ទាហានជើងទឹក ចែកជា ៣ ក្រុម

ក្រុមទី ១ ហៅទ័ពស្រួច ហាត់ច្បាំងនឹង ទូកដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វថ្ងៃ ។

ក្រុមទី ២ ហៅទ័ពជំនួយ ហាត់ច្បាំងនឹង ទូកចែវពីរជួរ ដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វ ថ្ងៃ ។

ក្រុមទី ៣ ហៅទ័ពបាសាក់ គឺទូកធំមានដំបូល មានចែវ មានក្តោង មានទ្រង់ទ្រាយដូចជាទូកបាសាក់ ហៅទូកប៉ុកចាយ តែរាងស្តួចវែងមាន ដំ-បូល តែមួយកាត់ខាងមុខឥតជញ្ជាំង - ល - ជាទូកដាក់ស្បៀងអាហារ សំ-រាប់កងទ័ព ។

របៀបបង្ហាត់ច្បាំង « តាមទំនៀមស្តេចត្រាញ់កម្ពុជាក្រោម » ស្តេចលើ មន្ត្រីបួនទិស « ចតុស្តម្ភ » ដែលនៅក្នុងឱវាទស្មិទ្ធិភូបាល ស្តេចត្រាញ់គ្រប់ជំពូក ដែលបញ្ញត្តិច្បាប់សំរាប់ស្រុក-ល- ។ កំណត់ថ្ងៃពេញបូណ៌មីខែកត្តិក រដូវអកអំបុកនោះ មន្ត្រីទាំងបួនទិសត្រូវកេណ្ឌទាហានទាំងជើងទឹកជើងគោក « សមយុទ្ធ » ១ ថ្ងៃ ១ យប់រាល់ឆ្នាំ ។

ចំណែកទាហានជើងទឹកអោយនៅប្រលងឫទ្ធិឯទន្លេពាមកន្លោ ក្នុងខេត្តឃ្លាំង ព្បិតទីនោះជាទីប្រជុំទឹក គ្រប់ខេត្ត ទៅមកបានស្រួល ។



www.budinst.gov.kh www.elibraryofcambodia.org

តាមសៀវភៅ និង ឯកសារ ជាប្រភពទាំងពីរខាងលើនេះ អាច សន្និដ្ឋានបានថា ប្រទេសកម្ពុជាសម័យបុរាណ ជាប្រទេសមានកងទ័ពជើង ទឹកយ៉ាងខ្លាំងពូកែ និង មានវិធីហ្វឹកហ្វឺន ពិធីសមយុទ្ធកងទ័ពនេះ ជាប្រពៃណី ជាប់រៀងរាល់ឆ្នាំ ហើយអាចសន្និដ្ឋានទៀតថា ប្រទេសកម្ពុជាធ្វើពិធីនេះ រៀងរហូតមក គឺជាប់តំណមកពីសមយុទ្ធ ក្នុងសម័យបុរាណនេះឯង ។

គ . ឯកសារខ្លះបាននិយាយថា ពិធីបុណ្យអុំទូក គឺជាបុណ្យ ប្រពៃណីជាតិ ដ៏ធំមួយនៅប្រទេសកម្ពុជា ។ បុណ្យនេះ មានរូបភាពប្រហាក់ ប្រហែលនឹងបុណ្យប្រចាំរដូវរបស់ជនជាតិអឺរ៉ុប ដែលមានឈ្មោះថា សាំង ហ្សង់ ដែលបច្ចុប្បន្នប្រារព្ធ ធ្វើនៅអឺរ៉ុបខាងជើង ។

៥ ប្រពៃណីខ្លះ មានប្រវត្តិជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងប្រវត្តិ នៃព្រះពុទ្ធជាម្ចាស់ ។ ប៉ុន្តែការបកស្រាយមួយ ដែលអាចយកជាការគ្រប់ គ្រាន់គឺក្នុងបំណង « ដឹងគុណដល់ព្រះគង្គា និង ព្រះធរណី ដែលបានផ្តល់ដល់ ជីវភាពរស់នៅ និងសុខមាលភាពចំពោះទឹកដីវិញ ដែលយើងនាំគ្នាធ្វើអោយ កករល្អក់ » ។

៦ ការបកស្រាយចុងក្រោយនេះ គឺដូចគ្នាបេះបិទទៅនឹង ទំនៀម ទំលាប់នៃព្រហ្មញ្ញសាសនា ហើយស្របទៅ នឹង ស្ថានភាពភូមិសាស្ត្រជាក់ ស្តែង និង ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាកសិករយើង ។

៧ ពិធីបុណ្យអុំទូក ប្រព្រឹត្តទៅនាថ្ងៃពេញបូណ៌មីខែកត្តិក ស្របទៅ នឹង រដូវទឹកជំនន់ ដែលក្នុងរយៈពេលប៉ុន្មានខែមកហើយបានធ្វើអោយបឹង បួរណ៍ទាំងឡាយក្លាយទៅសមុទ្រដ៏ធំល្វឹងល្វើយហើយក៏បញ្ជាក់ទៀតថា ពេល នេះស្រូវក្នុងស្រែកំពុងតែទុំហើយ ។

« នៅពេលដែលទឹកទន្លេមេគង្គលិចជន់ « សីហា. វិច្ឆិកា » ទឹក



www.budinst.gov.kh www.elibraryofcambodia.org

ជំនន់ដ៏សន្ធឹកសន្ធាប់ បានហូរចាក់ស្រោចស្រព្វបឹងបួរ តាមរយៈទន្លេសាប ដែលហូរពីត្បូង មៅជើង ។ ដល់រដូវទឹកស្រក ដែលចាប់ផ្ដើមនៅខែវិច្ឆិកាទឹក បឹងបួរហូរ ត្រឡប់តាម ទន្លេសាបដដែល ពីជើងមកត្បូងវិញ » ។

ទឹកជំនន់នៃទន្លេមេគង្គ ពិសេសជំនន់នៅតាមបឹងបួរមានប្រភព មកពីប្រទេសទីបេដ៏សែនឆ្ងាយ បានផ្ដល់ជីវភាពនូវស្រែចំការនៅប្រទេស កម្ពុជា ។ ដី ល្បាប់ដែលបានដោយសារទឹកជំនន់នៃទន្លេបឹងបួរ ទាំងឡាយបាន ធ្វើអោយ ដីមាន ជីជាតិបង្កបាននូវធនធានសំបូរបែបនៅក្នុងប្រទេសកម្ពុជា ។

ដំណាំទាំងឡាយដែលកសិករខ្មែរធ្វើតាមចង្វាក់នៃទឹកសំរកបាន ផ្ដល់នូវផលយ៉ាងច្រើន រាំងស្កាត់គ្រោះទុរ្ភិក្ស និង ផ្ដល់សុភមង្គល ។ ដូច្នេះ ហើយបានជាដល់រដូវទឹកស្រក បុរាណខ្មែរយើង ក៏កំណត់យកថ្ងៃពេញ បូណ៌មី ខែកត្ដិករៀងរាល់ឆ្នាំ រៀបចំពិធីអុំទូក បណ្ដែតប្រទីប សំពះព្រះខែ អកអំបុក ដើម្បីសំដែងមនោសញ្ចេតនាដឹងគុណចំពោះទន្លេមេគង្គ និង ទន្លេសាប ដែលបានផ្ដល់ជីជាតិយ៉ាងសំខាន់បំរើវិស័យកសិកម្ម ។

ពិធីបុណ្យនេះ គេតែងប្រារព្ធធ្វើអស់ថេរវេលា ៣ ថ្ងៃ គឺថ្ងៃ ១៤ កើត ១៥ កើត និង ថ្ងៃ ១ រោជ ខែ កត្ដិក ធ្វើនៅតាមដងទន្លេសាប នាកំពង់ផែ មុខវាំង ។

## ប្រភពពិធីបណ្ដែតប្រទីប

ក. គម្ពីរ ទាថាវង្ស ភាសាបាលី មានចែងថាព្រះចង្កូមកែវទាំងបួន នៃព្រះសម្មាសម្ពុទ្ធប្រតិស្ឋាននៅទីទាំង ៤ គឺ



www.budinst.gov.kh www.elibraryofcambodia.org

ទី ១ - នៅត្រៃត្រឹង្សស្ថិត,

ទី ២ - នៅពិភពនាគ,

ទី ៣ - នៅស្រុកគន្ធារ,

ទី ៤ - នៅទន្តបុរៈ កលិង្គរដ្ឋ ។

ខ - ភាណវារៈបាលី ត្រង់ពុទ្ធនមក្ការគាថា មានចែងថាស្នាមព្រះ-បាទ ព្រះសម្មាសម្ពុទ្ធប្រតិស្ឋាននៅទីទាំង ៥ គឺ

ទី ១ - នៅសុវណ្ណមាលិកបរពត

ទី ២ - នៅសុវណ្ណបរពត

ទី ៣ - នៅសុមនកូដបរពត

ទី ៤ - នៅយោនកបុរី

ទី ៥ - នៅស្ទឹងនម្មទា ។

៩ គ - ពាក្យសរសើរព្រះបាទ « យស្សបាទេ » ទាំងបាលិ ទាំងសម្រាយមានចែងថា ព្រះបាទនៃព្រះសម្មាសម្ពុទ្ធប្រតិស្ឋាននៅទីទាំង ៥ ដូចក្នុងភាណ វារៈ ដែរ ។

ដោយហេតុមានគម្ពីរដីកាជាប្រភពយ៉ាងនេះ បានជាពុទ្ធបរិស័ទខេមរជាតិតែងធ្វើពិធីបណ្តែតប្រទីបនៅយប់ពេញបូណ៌មីខែអស្សុជ , ដែលក្រោយមកគេ ប្រារព្ធពិធីបណ្តែតប្រទីបនៅយប់ ១៤ - ១៥ កើត និង ១ រោជខែកត្តិក បូជាចំពោះព្រះចង្កូមកែវ នៅពិភពនាគ ព្រះពុទ្ធបាទនៅស្ទឹងនម្មទា និង នៅទីឯទៀតដូចពោលខាងលើ ហើយដោយជឿថា ជាការកុសលយ៉ាងធំបានផលយ៉ាងប្រសើរ ដើម្បីសុខចំរើនរុងរឿងដល់ខ្លួន ដល់ប្រជាជន និង ដល់ប្រទេសជាតិ ។



www.budinst.gov.kh www.elibraryofcambodia.org

## ប្រភពនៃពិធីសំពះព្រះខែ - អកអំបុក :

តាមគម្ពីរបរមត្ថទីបនី អដ្ឋកថាចរិយាបិដក ភាសាបាលីមានចែងថា ក្នុងដើមភទ្ទកប្បនេះ ព្រះបរមពោធិសត្វនៃយើង ទ្រង់យោនយកកំណើតជាសសពណ្ឌិត « កំណើតជាទន្សាយ » ។ នៅថ្ងៃពេញបូរណ៍មីមួយ សស-បណ្ឌិត បានអធិដ្ឋានឧបោសថសីល · ហើយឧទ្ទិសចំសះជាទានបរមត្ថបារមីដើម្បីបំពេញពោធិសម្ភារអោយបានត្រាស់ជាព្រះពុទ្ធ ។ ព្រះឥន្ទទ្រង់ជ្រាបហេតុការណ៍នោះ ក៏ទ្រង់ក្រឡាខ្លួនជាព្រាហ្មណ៍ចាស់មកសុំមំសាសសបណ្ឌិតជាអាហារសសបណ្ឌិតពោធិសត្វបានអោយ ព្រាហ្មណ៍ចាស់នោះបង្កាត់ ភ្លើងភ្លក់ ហើយក្នុងពេលដែលភ្លើងកំពង់ឆេះសន្ធោសន្ធៅ សសបណ្ឌិតក៏រលាស់ខ្លួន ៣ ដងដើម្បី អោយសត្វល្អិតដែលជាប់នៅនឹងរោមជ្រុះចេញ រួច ក៏លោតចូលទៅក្នុងភ្នក់ភ្លើងភ្លាម ។ អស្ចារ្យភ្លើងនោះ ពុំបានឆេះសសបណ្ឌិតសោះឥន្ទព្រាហ្មណ៍ក៏ស្ទុះទៅពរព្រះពោធិសត្វឡើងទៅដល់មណ្ឌលព្រះចន្ទ ហើយទ្រង់យកម្នាងសិលាគូររូបទន្សាយ ហើយឥន្ទព្រាហ្មណ៍អធិដ្ឋានថា សូមអោយរូបទន្សាយពោធិសត្វដែលខ្ញុំគូរនេះនៅជាប់រហូតដល់ទីបំផុតកប្ប ។

ដោយអានុភាពទានបរមត្ថបារមីនៃព្រះពោ[illegible]ផង និង សេចក្តីអធិដ្ឋានរបស់ព្រះឥន្ទផង រូបទន្សាយ ក៏ឃើញប្រាកដក្នុងមណ្ឌលព្រះចន្ទដរាបដល់សព្វថ្ងៃ ។

ដោយជឿតាមរឿងនេះហើយ បានជានៅវេលាយប់ពេញបូណ៌មីខែកត្តិក រៀងរាល់ឆ្នាំ ខ្មែរយើងយកនំចំណី មានអំបុក និង ចេកជាដើមមកបូជាព្រះច័ន្ទ ហៅថាពិធីសំពះព្រះខែ - អកអំបុក ។

*អត្ថបទរបស់ : នាយកដ្ឋានសាសនានៃខុទ្ទកាល័យក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា*



www.budinst.gov.kh www.elibraryofcambodia.org

# ពិធីបុណ្យអុំទូក និង ចំណាក់ផ្កាក់ទូក ឆ្នាំ ១៩៩០

ក្នុងឆ្នាំ មមី ទោស័ក ព.ស ២៥៣៤ គ.ស ១៩៩០ គឺ ជាឆ្នាំមាន អត្ថន័យជាប្រវត្តិសាស្ត្រដែលគណៈបក្សប្រជាជនកម្ពុជា រដ្ឋាភិបាល នៃ រដ្ឋកម្ពុជា និង រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា បានធ្វើអោយ រស់ឡើងវិញនូវពិធីបុណ្យ ប្រពៃណីរបស់ខ្លួន គឺបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ដែលមិនត្រូវបានគេអើពើពីឆ្នាំ ១៩៧០ ក្នុងអំឡុង សង្គ្រាម ៥ ឆ្នាំ នៃរបប លន់ ណុល និង ត្រូវហាមឃាត់ដាច់ខាតក្នុងចន្លោះ ឆ្នាំ ១៩៧៥ - ១៩៧៨ នៅក្រោមរបបគ្រប់គ្រងផ្តាច់ការរបស់ពួក ប៉ុលពត ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ , គណៈបក្សប្រជាជនកម្ពុជា និង រដ្ឋា-ភិបាលនៃរដ្ឋកម្ពុជា បានបើកឱកាសជូនប្រជាជនរក្សាប្រពៃណីជាតិ កំសាន្ត សប្បាយនៅតាមវត្តអារាម តាមជនបទ ភូមិ ឃុំ ជារៀងរាល់ឆ្នាំ ហើយចាប់ពី ឆ្នាំ មមី ទោស័ក ព.ស ២៥៣៤ គ.ស ១៩៩០ គណៈបក្ស រដ្ឋាភិបាល និង រណសិរ្ស បានកំណត់យកពិធីបុណ្យនេះជាផ្លូវការតទៅ ។

ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុកមាន អត្ថន័យពីរយ៉ាង ម៉្យាងគឺការថែរក្សាប្រពៃណី ទំនៀមទំលាប់ជាតិដ៏ល្អប្រពៃ និង ជំនឿសាសនារបស់ប្រជាជនយើង ហើយម៉្យាងទៀត គឺជាការបញ្ជាក់ កាន់តែច្បាស់ពីអត្ថិភាព និង ការរីកចំរើនលើគ្រប់វិស័យ នៃសង្គមជាតិដែល


www.budinst.gov.kh www.elibraryofcambodia.org

យើងសំរេចបានហើយត្រូវខិតខំការពារថែរក្សាអោយគង់វង្សជារៀងរហូត។

ការប្រណាំងទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក គឺជាពិធីបុណ្យដ៏ល្អប្រពៃរបស់ប្រជាជាតិយើង, ដែលបង្ហាញពីទឹកចិត្តជាបុណ្យកុសល ស្រឡាញ់ភាពសុខក្សេមក្សាន្ត សប្បាយរីករាយសាមគ្គីភាពទូលំទូលាយ និង ក៏ជាការឆ្លុះបញ្ចាំងពីថាមពលក្លៀវក្លា ស្វាហាប់ ម៉ឺងម៉ាត់ អង់អាចក្លាហាន អំណត់ព្យាយាម និង ឆន្ទៈ ប្រយុទ្ធរបស់ប្រជាជនយើងក្នុងការការពារឯករាជ្យជាតិ ការពារអាយុជីវិតប្រជាជន ទ្រព្យសម្បត្តិ កេរដំណែល និង កិត្តិយសរបស់ជាតិ ប្រឆាំងនឹងគ្រប់ឧបាយកលល្បិចពានរបស់ខ្មាំងសត្រូវ ។ ម៉្យាងទៀត ពិធីនេះក៏ជាការបង្ហាញពីការរីកចំរើនសំបូរបែបនៃផលិតផលកសិកម្ម ដែលផុសចេញពីទឹក ដីដ៏មានជីវជាតិនៃប្រជ្រោយសុវណ្ណភូមិ គួបផ្សំនឹងចរិតឧស្សាហ៍ព្យាយាម អត់ធ្មត់ កែច្នៃចម្លជាតិ មិនគិតពីការនឿយហត់របស់ប្រជាជនយើង ។

គួរគប្បីរំលឹកឡើងវិញថា នារសៀលថ្ងៃទី ២ វិច្ឆិកា ១៩៩០ ការប្រណាំងទូកង ទូកម៉ូង នៅតាមដងទន្លេសាប នៅត្រង់ចតុមុខ មានទូកចំនួន ៤៣ មកពីបណ្តាខេត្ត ក្រុង និង អង្គភាពមួយចំនួន គឺ ទីក្រុងភ្នំពេញ ៩ ទូក,ខេត្តកណ្តាល ១៥ ទូក , ខេត្តកំពង់ចាម ៦ ទូក,ខេត្ត ព្រៃវែង ៤ ទូក, ខេត្តកំពង់ឆ្នាំង ៤ទូក , ខេត្តក្រចេះ ២ ទូក និងស្នងការជើងទឹក ៣ ទូក ។ ទូកទាំង ៤៣នេះ ត្រូវបានផ្គូរផ្គងប្រណាំងផ្តាច់ព្រ័ត្រនៅថ្ងៃទី៣ វិច្ឆិកា ១៩៩០ តាមគូរ ៧ ដែលគណៈកម្មការបានកំណត់បែងចែក ដូចទៅនេះ :

## គូទី១

. កំពែងពេជ្រឃ្លោញ វត្តឃ្លោញ ស្រុកឫស្សីកែវ រដ្ឋធានីភ្នំពេញ



www.budinst.gov.kh www.elibraryofcambodia.org

ចំណោះ ៤៧ នាក់

- ច័ន្ទរស្មីពស់ព្រៃមានឬទ្ធិ វត្តមេសប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង ចំណុះ ៤០ នាក់

## គូទី ២

- កំហែងបារមី វត្តក្រៅ ឃុំភូមិធំ ខេត្តកណ្ដាល ចំណុះ ៥៦ នាក់
- ព្រួញពេជ្រ ខ័ណ្ឌចំការមន រដ្ឋធានីភ្នំពេញ ចំណុះ ៥០នាក់

## គូទី ៣

- សុវណ្ណមច្ឆាបុប្ផាពេជ្រ វត្តត្បូងដំរី ខ្សាច់កណ្ដាល ខេត្តកណ្ដាល ចំណុះ ៣៨ នាក់
- សុវណ្ណឈ្លូកវ័ត្ត វត្តកញ្ចក់ ខ័ណ្ឌ ចំការមន រដ្ឋធានីភ្នំពេញ ចំណុះ ៤៥ នាក់

## គូទី ៤

- ចំប៉ាពេជ្រ វត្តចុងកោះ ខេត្តកំពង់ចាម ចំណុះ ៣៨ នាក់
- ពេជ្រម្កុដរស្មីផ្កាយព្រឹក វត្តស្លាកែត ឃុំគគីរ ខេត្តកណ្ដាល ចំណុះ ៥៦ នាក់

## គូទី ៥

- មហានាគ វត្ត នាគវ័ន ខ័ណ្ឌទួលគោក រដ្ឋធានីភ្នំពេញ ចំណុះ ៤៥ នាក់
- ចិន្ដាមុនី វត្តពោធិ៍ហស់ ឃុំ ជ្រៃធំ ខេត្ត កណ្ដាល ចំណុះ ៤៥នាក់



www.budinst.gov.kh www.elibraryofcambodia.org

## គូទី ៦

- បទុមរិទ្ធិ វត្តបុទមវត្តី ឃុំ ស្វាយឃ្លាំង ខេត្តកំពង់ចាម

- រតនមុន្នី ស្រវ៉ៃនផ្កាយព្រឹក វត្តព្រៃកក្មេង ខ័ណ្ឌ ៧ មករាជធានីភ្នំពេញ ចំណុះ ៤៣ នាក់

## គូទី ៧

- កំពែងរាមា វត្តក្រៅ ឃុំភូមិធំ ខេត្តកណ្ដាល ចំណុះ ៥៦ នាក់

- លំពែងពេជ្រ វត្តសេរីគង្គា ខេត្តកំពង់ចាម ចំណុះ ៥២ នាក់

## គូទី ៨

- ពេជមុន្នីរត វត្តវាលអណ្ដែត ឃុំកោះរះ ល្វាឯម ខេត្តកណ្ដាល ចំណុះ ៤៦ នាក់

- សុវណ្ណពេជ្រគីរី វត្តចាក់អង្រែ ស្រុកមានជ័យ រដ្ឋធានីភ្នំពេញ ចំណុះ ៥៥ នាក់

## គូទី ៩

- សារាយផុត វត្តពិជ័យរង្សីពុកឫស្សី ខេត្ត កណ្ដាល ចំណុះ ៤១ នាក់

នារី ឧត្តម ស្រុកកងមាស ខេត្តកំពង់ចាម

## គូទី ១០

- ស្រីខ្មៅមានជ័យ វត្តត្រាល ស្រុកពារាំង ព្រៃវែង ចំណុះ ៤២ នាក់



www.budinst.gov.kh www.elibraryofcambodia.org

- បទុមបុប្ផា វត្ត បទុមកេសរ ពាមកោះស្នា ស្រុក ស្ទឹងត្រែង ខេត្ត កំពង់ចាម ចំណុះ ៤៣ នាក់

## ភូមិ ១១

- ភ្នំប្ញរីសេរីរិទ្ធិ វត្តព្រែកក្របៅ មន្ទីរឃោសនាការ និងវប្បធម៌ រដ្ឋធានី ភ្នំពេញ ចំណុះ ៥៥ នាក់

- ចំប៉ាពេជ្រ ខេត្តក្រចេះ ចំណុះ ៣៩ នាក់

## ភូមិ ១២

- រិទ្ធីចេស្តារកុមារពេជ្រ វត្តមេបាន ស្រុកខ្សាច់កណ្តាល ខេត្ត កណ្តាល ចំណុះ ៤៥ នាក់

- ចំរើនរិទ្ធិ ខេត្តក្រចេះ ចំណុះ ៣៦ នាក់

## ភូមិ ១៣

- សង្គមផ្កាយព្រឹក វត្តព្រែកជ្រៃលើ ឃុំព្រែកជ្រៃ ស្រុកពាមរ ខេត្ត ព្រៃវែង ចំណុះ ២៦ នាក់

- ជ័យជំនះ ស្នងការជើងទឹក ចំណុះ ៣១ នាក់

## ភូមិ ១៤

- រន្ទះសូរសែង វត្តក្រឡែងកែង ឃុំវាលស្បូវ ស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចំណុះ ២៩ នាក់

- ព្រួញមាស ស្រុកស្រីសន្ធរ ខេត្ត កំពង់ចាម ចំណុះ ៣៩ នាក់



www.budinst.gov.kh www.elibraryofcambodia.org

## គូទី ១៥

- ពេជ្រមុនី វត្តពោធិឧត្តម ឃុំព្រែករន្ទះ ខេត្ត ព្រៃវែង ចំណុះ ៤០ នាក់

- រន្ទះពេជ « ក្តាមប្រៃ » វត្តកំពង់ត្រឡាច កំពង់ក្តាម ស្រុកកំពង់ត្រឡាច ខេត្ត កំពង់ឆ្នាំង ២៦ នាក់

- យកជ័យ វត្តទីបាវសាន ស្ទឹងការដើងទឹក ចំណុះ ៣៨ នាក់

## ទូកថែបនារី : គូទី ១៦

- ពេជ្របុប្ផា មានជ័យ វត្តក្រពុំពេជ្រ កោះដាច់ ខេត្តកណ្តាល ចំណុះ ៤៦ នាក់

- ពេជរិទ្ធិសាមគ្គីមានជ័យ ខេត្តកណ្តាល ចំណុះ ៤៦ នាក់

## គូទី ១៧

- មានជ័យ វត្តក្បាលកោះ ស្ទឹងការដើងទឹក ចំណុះ ២៨ នាក់
- រំភាយផាត់មានរិទ្ធិ វត្តរកាកោង មុខកំពូល ខេត្តកណ្តាល

## គូទី ១៨

- សុវណ្ណកែវមុនី វត្តកែវមុនីជោត មុខកំពូល ខេត្តកណ្តាល ចំណុះ ៤៨ នាក់

- ចំប៉ាមានរិទ្ធ វត្តស្រះចក ខេត្តកំពង់ឆ្នាំង ចំណុះ ២៣ នាក់

## គូទី ១៩

- ក្រពុំពេជ្រ ខេត្តកណ្តាល ចំណុះ ២៩ នាក់



www.budinst.gov.kh www.elibraryofcambodia.org

- ប្រពៃស្រេព វត្តប្រពៃស្រេព កំពង់ឆ្នាំង ចំណុះ ២៦ នាក់

## គូទី ២០

- មហាគ្រុឌរិទ្ធិ វត្តចតុមុខារាម មុខកំពូល ខេត្ត កណ្ដាល ចំណុះ ២៦ នាក់

- កំហែងពេជ្រ វត្តឥន្ទលិបូណ៌ ខ្សាច់កណ្ដាល ខេត្ត កណ្ដាល ចំណុះ ២៩ នាក់

## គូទី ២១

- សេរីមានរិទ្ធិ ខេត្តកណ្ដាល ចំណុះ ៤៣ នាក់

- សុវណ្ណផលសា វត្តរកាកោង ខេត្តកណ្ដាល

ក្រោយពេលព្រលប់ ពិធីពីរទៀតក៏ត្រូវបានធ្វើអោយរស់ឡើងវិញ គឺការលយប្រទីបតាមដងទន្លេកាត់ពីមុខអតីតវាំង និង ការសំពះព្រះខែ អកអំបុកនៅពាក់កណ្ដាលអធ្រាត្រក្នុងអតីតវាំង ។

ក្រោយពីពេលប្រណាំងគ្នាចំងាយផ្លូវទឹក ១.៥០០ ម យ៉ាងស្វាហាប់ និងស្វិតស្វាញ ចំនួន ៣ លើករួចមក, ពិធីប្រណាំងទូកផ្ដាច់ព្រ័ត្របានបន្តមោរសៀលថ្ងៃទី ៣ វិច្ឆិកា ទៀត ។

ជាលទ្ធផល បច្ចេកទេសនៃការប្រណាំងផ្ដាច់ព្រ័ត្រ, ទូកអុំ និង ទូកចែវ ត្រូវបានទទួលចំណាត់ថ្នាក់ ដូចតទៅ ៖

### ក - ទូកអុំផ្នែកបុរស ៖

- លេខ ១ « បទុមបុប្ផា » វត្តបទុមកេសរ ឃុំពាមកោះស្នា ស្រុក



www.budinst.gov.kh www.elibraryofcambodia.org

ស្ទឹងត្រង់ ខេត្តកំពង់ចាម

ល្បឿន ៩ នាទី ២៧ វិនាទី ៧ ភាគ ១០

- លេខ ២ « ព្រួញមាស » ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ល្បឿន ៩ នាទី ៣៦ វិនាទី ៩ ភាគ ១០

- លេខ ៣« ចំប៉ាពេជ្រ » ខេត្តក្រចេះ ល្បឿន ៩នាទី ៤៧ វិនាទី

## ខ . ទូកចែវថ្ងៃកបុរស :

- លេខ ១ « ក្រពុំពេជ្រ » វត្តក្បាលកោះ ឃុំឧកញ្ញាតី ស្រុកខ្សាច់ កណ្តាល ខេត្តកណ្តាល ល្បឿន ១០ នាទី ៤៤ វិនាទី ៦ ភាគ ១០

- លេខ ២ « ប្រពៃស្រេព » វត្តប្រពៃស្រេព ឃុំជលសា ស្រុកជលគីរី ខេត្ត កំពង់ឆ្នាំង ល្បឿន ១០ នាទី៤៥ វិនាទី ៨ ភាគ ១០

- លេខ ៣ « សេរីមានរិទ្ធិ » វត្តពិជ័យរង្សី ឃុំ ពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ល្បឿ ន ១១ នាទី ០០ វិនាទី

## គ . ទូកចែវថ្ងៃកនារី :

- លេខ ១ « ពេជ្ររិទ្ធិសាមគ្គីមានជ័យ » វត្តកោះដាច់ ស្រុកមុខកំពូល ខេត្ត កណ្តាល ល្បឿន ១២ នាទី ៥១ វិនាទី

- លេខ ២ « ពេជ្របុប្ផាមានជ័យ » វត្តកោះដាច់ ឃុំ កោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ល្បឿន ១៣ នាទី ៣១ វិនាទី ៨ ភាគ ១០ ។

នៅក្នុងពិធីដ៏មហោឡារិកនេះ ឯកឧត្តម **ហេង សំរិន** ប្រធានក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា បានអញ្ជើញចូលរួមជាអធិបតី និងបានជូនរង្វាន់ដល់ជ័យលាភីទាំងនោះផង ។

**ឌិម ខែម**



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org